

# រឿងទី៧៖ ការមានព្រះជន្មរស់ឡើងវិញ

## ខគម្ពីរ៖ យ៉ូហាន១១:២៥-២៦

២៥ ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ «ខ្ញុំហ្នឹងហើយដែលប្រោសមនុស្សអោយរស់ឡើងវិញ ខ្ញុំនឹងផ្ដល់អោយគេមានជីវិត។ អ្នកណាជឿលើខ្ញុំ ទោះបីស្លាប់ទៅហើយក៏ដោយ ក៏នឹងបានរស់ជាមិនខាន។ ២៦ រីឯអស់អ្នកដែលកំពុងតែមានជីវិតនៅរស់ ហើយជឿលើខ្ញុំ មិនស្លាប់សោះឡើយ តើនាងជឿសេចក្ដីនេះឬទេ?»

ក្រោយពេលព្រះយេស៊ូទ្រង់សុគតលើឈើឆ្កាងភ្លាម ពួកសាវ័ករបស់ទ្រង់ និងអ្នកដែលដើរតាមព្រះយេស៊ូទាំងអស់មានទុក្ខ សោកជាទម្ងន់។

ចំណែកឯមហាបូជាចារ្យ និងពួកមេដឹកនាំនៃចក្រភពរ៉ូម ពួកគេបានចាំពាក្យដែលព្រះយេស៊ូមានបន្ទូលពេលទ្រង់នៅមានព្រះជន្មថាទ្រង់នឹងមានព្រះជន្មរស់ឡើងវិញ ដូច្នេះពួកគេបានបញ្ជាឱ្យពួកទាហានយកថ្មដ៏ធំធ្ងន់មកបិទមាត់ផ្នូរហើយចាំយាមផ្នូររបស់ព្រះយេស៊ូទាំងយប់ទាំងថ្ងៃ។

នៅថ្ងៃទីបី ក្រោយព្រះយេស៊ូសុគត នាងម៉ារី ជាអ្នកស្រុកម៉ាក់ដាឡា និងនាងម៉ារីជាម្ដាយយ៉ាកុបនិងសាឡូមេ ជាអ្នកដើរតាមព្រះយេស៊ូបានក្រោកពីព្រលឹមទៅផ្នូរដែលមានព្រះសពព្រះយេស៊ូ។ ពួកនាងបាននាំយកគ្រឿងក្រអូបទៅជាមួយ ដើម្បីអប់ព្រះសពព្រះយេស៊ូ។

ពេលទៅដល់ផ្នូរ ពួកនាងឃើញថ្មបានរមៀលចេញពីមាត់ផ្នូរ ឃើញថានៅក្នុងផ្នូរទទេស្អាត។ ពួកនាងរកព្រះសពព្រះយេស៊ូមិនឃើញទាល់តែសោះ។

ប៉ុន្តែ ពួកនាងបែរជាឃើញមានទេវតាពាក់សកំពុងអង្គុយនៅកន្លែងដាក់ព្រះសពព្រះយេស៊ូទៅវិញ។

ទេវតានោះមានប្រសាសន៍ទៅពួកស្ត្រីនោះថា៖ «កុំភ័យស្រឡាំងកាំងធ្វើអ្វី! ដ្បិតយើងដឹងថាពួកនាងមករកព្រះយេស៊ូដែលបានឆ្កាងនៅលើឈើឆ្កាងនោះ។ ព្រះយេស៊ូទ្រង់មានព្រះជន្មរស់ឡើងវិញហើយ»។ ស្ត្រីទាំងនោះបាននាំដំណឹងដ៏អំណរនេះរត់ទៅប្រាប់គេឯង។ ពេលកំពុងរត់ទៅ ពួកនាងបានជួបនិងមនុស្សម្នាក់។ ហើយមនុស្សម្នាក់នោះ គឺជាព្រះយេស៊ូ។

ស្ត្រីទាំងនោះ មានចិត្តអរសប្បាយយ៉ាងខ្លាំង ក៏លុតជង្គង់ឱនក្រាបចាប់ជើងទ្រង់ហើយគោរពទ្រង់។

នៅល្ងាចថ្ងៃនោះ ពួកសាវ័កទាំងអស់ បានមកប្រជុំគ្នានៅក្នុងបន្ទប់លើដំបូលផ្ទះមួយនៅក្រុងយេរូសាឡឹម។

ពួកគេបានចាក់សោរទ្វារយ៉ាងជាប់ ព្រោះខ្លាចពួកទាហានរ៉ូម៉ាំងមកចាប់ពួកគេ។ ពេលនោះ ព្រះយេស៊ូក៏លេចឡើងនៅចំពោះពួកសាវ័កទាំងអស់។

ពេលឃើញព្រះយេស៊ូភ្លាម ពួកសាវ័កទាំងអស់ភ័យតក់ស្លុត ញ័រខ្លួនយ៉ាងខ្លាំង ព្រោះស្មានតែខ្មោចលង។ ពេលនោះព្រះយេស៊ូក៏មានបន្ទូលថា៖

«ហេតុអ្វីបានជាអ្នករាល់គ្នាទន់ចិត្តដូច្នេះ? អ្នករាល់គ្នាបានឃើញខ្ញុំហើយ តើនៅសង្ស័យពីការមានព្រះជន្មរស់ឡើងវិញរបស់ខ្ញុំទៀតឬ? ចូរអ្នករាល់គ្នាស្ទាបមើល»។ ទីបំផុត ពួកសាវ័កទាំងអស់ ក៏ជឿថាព្រះយេស៊ូពិតជាមានព្រះជន្មរស់ពីសុគតពិតមែន។

ហើយពួកគេក៏បានលុតជង្គង់ថ្វាយបង្គំព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ។

ព្រះយេស៊ូបានមានបន្ទូលទៅពួកសាវ័កទាំងអស់ថា៖ «ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍អោយធ្វើជាសិស្ស ហើយធ្វើពិធីជ្រមុជទឹកអោយគេ ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ ត្រូវបង្រៀនគេអោយប្រតិបត្តិតាមសេចក្ដីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា។ ចូរដឹងថា ខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃ រហូតដល់អវសានកាលនៃពិភពលោក»។

ព្រះយេស៊ូបានសន្យាថា នៅថ្ងៃចុងក្រោយនៃផែនដីនេះ ទ្រង់នឹងជិះពពកយាងមកម្ដងទៀត ដើម្បីជំនុំជំរះ។





**សកម្មភាពទី១** សូមឆ្លើយនិងសំណួរខាងក្រោម។



a. ក្រោយពីព្រះយេស៊ូបានសោយទិវង្គតហើយ តើពួកមហាបូជាចារ្យ និងពួកអ្នកដឹកនាំបាននឹកឃើញពីព្រះបន្ទូលអ្វី ដែលព្រះយេស៊ូមានបន្ទូល?

b. តើស្ត្រីណាខ្លះ ដែលបានឃើញផ្នូររបស់ព្រះយេស៊ូនៅទទេរ?

c. សូមអានព្រះគម្ពីរម៉ាថាយ២៨:១៦-២០ រួចឆ្លើយនិងសំណួរ។ តើព្រះយេស៊ូបានបង្គាប់ឱ្យពួកសាវកទ្រង់ធ្វើអ្វី?

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញឱ្យចាំ(យ៉ូហាន១១:២៥)

**-ខ្ញុំហ្នឹងហើយដែលប្រោសមនុស្សអោយរស់ឡើងវិញ ខ្ញុំនឹងផ្តល់អោយគេមានជីវិត។ អ្នកណាជឿលើខ្ញុំ ទោះបីស្លាប់ទៅហើយក៏ដោយ ក៏នឹងបានរស់ជាមិនខាន**

**សកម្មភាពទី២** ស្វែងរកពាក្យ៖ សូមស្វែងរកពាក្យដែលនៅក្នុងតារាងខាងក្រោម។

**រស់ឡើងវិញ ព្រះយេស៊ូ ទេវតា ទីបញ្ចុះសព ស្ត្រីទាំងនោះ ម៉ារីជាអ្នកស្រុកម៉ាដាឡា ដំណឹងដ៏រីករាយ**



| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| មួយ | ចាំ | ចោល | ចូរ | ទោះ | ទើប | សោះ | គួរ | ដាំ | ធំ | លើ | ព្រះ | យេ | ស៊ូ | ថ្នាំ | រាប់ |
| ពិ | ទេវ | យាយ | បាក | កុំ | ទាប | សួរ | យូរ | គេ | ចោះ | កុ | ខំ | អំ | ប្រ | នូត | សុំ |
| និ | ច្រ | តា | តំ | យោ | ទៅ | រក | យប់ | អំ | ខ្ពស់ | ឈឺ | ថ្មម | ត្រង់ | ក្រ | លេង | មា |
| រឿង | ល់ | យេ | រក្សា | បល់ | ចូរ | រាវ | ជ្រៅ | រីក | ស្រ | ឡា | មើល | ខ្លាំង | រស់ | ខ្ទះ | ជា |
| ទាន | ដាប់ | ព្រះ | ម៉ា | រី | ជា | អ្នក | ស្រុក | ម៉ា | ដា | ឡា | លេង | លើ | ម៉េ | ឡើង | ឃុំ |
| ទាំ | ចូល | បន្ទូល | ថៃ | ទាំង | ចេះ | សម | រិ | តំ | ក្ដី | គូ | រិ | សព | អ្នក | ធ្លាប់ | វិញ |
| ឆារ | ក្នុង | នោះ | លូត | ប្រ | ឆា | បាច់ | ចាំ | ហាំ | មេ | ចាំ | បញ្ចុះ | ប្រា | ក្រី | បើក | ខំ |
| រាំ | ទាំង | ខ្យត់ | ផុះ | តំ | ណើ | បើង | ទ្រាំ | ដៃ | បិ | ទី | ថ្ងៃ | ចង់ | ជា | ទ្វារ | បុ |
| ស្ត្រី | សង់ | អត់ | នើប | ដី | ដំ | ណឹង | ដ៏ | រីក | រាយ | ប្រ | ពិ | បី | ធំ | ស្ពាន | ស្ទូរ |